**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ : ១៧៤/១៣ ក.អ.ជ.សស៩

ថ្ងៃចន្ទ ៩ កើត ខែមិគសិរ ឆ្នាំម្សាញ់ ព.ស. ២៥៥៧
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា គ.ស. ២០១៣

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ
## របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងសេចក្តីសម្រេចលេខ ០០៣/១១ ល.ស អ.ប.ព របស់អង្គភាពប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១១ ស្តីពីទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល
- យោងសេចក្តីជូនដំណឹងលេខ ០២៥/១៣ សជណ.អបព របស់អង្គភាពប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីកម្មវិធីប្រកាសទ្រព្យសម្បត្តិ និងបំណុល ឆ្នាំ២០១៤ នៅតាមក្រសួង-ស្ថាប័ន

## សម្រេច

**ប្រការ ១** .- កែសម្រួលក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តមបណ្ឌិត | **ថោង ចំនួនសុទ្ធារ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម | **ប៊ុន ចំនួនវណ្ណៈ** | អគ្គាធិការ | អនុប្រធាន |
| ៣. លោក | **សុខ សុផល** | អគ្គនាយករងបច្ចេកទេស | សមាជិក |

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

| | | | |
|---|---|---|---|
| ៤. លោក | **ឆួន តិរម្យ** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៥. លោក | **ពេជ្រ សេដ្ឋា** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៦. លោក | **ហួ កុលច័ន្ទ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៧. លោក | **លាត សំណាង** | ប្រធាន ន.បណ្តុះបណ្តាល និងស្រាវជ្រាវ | សមាជិក |

**ប្រការ ២** .- ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ មានតួនាទី និងភារកិច្ច ដូចតទៅ ÷

១. ទំនាក់ទំនង និងសហការដោយផ្ទាល់ជាមួយ អ.ប.ព. ក្នុងការអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ

២. ទទួលបន្ទុករាល់ការងារពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ និងបំណុល ដូចជាធ្វើបញ្ជីឈ្មោះអ្នកត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងក្រសួងអភិវឌ្ឍន៍ជនបទ រួចបញ្ជូនមក អ.ប.ព.។ ផ្សព្វផ្សាយគោលការណ៍ណែនាំអំពីការប្រកាសទ្រព្យសម្បត្តិ និងបំណុល និងរៀបចំបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិទាំងអស់មក អ.ប.ព.។ល។

៣. តាក់តែង និងឆ្លងឯកឧត្តមរដ្ឋមន្ត្រី នូវក្រមសីលធម៌ផ្ទៃក្នុងក្រសួងអភិវឌ្ឍន៍ជនបទ រួចបញ្ជូនមក អ.ប.ព.។

៤. (១) រៀបចំ និងដាក់ឆ្លងរដ្ឋមន្ត្រីនូវផែនការសកម្មភាពប្រឆាំងអំពើពុករលួយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ (២) ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពនេះ (៣) ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារអនុវត្តផែនការសកម្មភាពនេះ ដើម្បីដាក់ជូន អ.ប.ព. (៤) ចូលរួមប្រជុំបូកសរុបលទ្ធផលការងារអនុវត្តផែនការសកម្មភាពនេះជាមួយ អ.ប.ព. និង (៥) ទទួល និងអនុវត្តតាមការណែនាំបន្ថែមនានាទាក់ទងនឹងផែនការសកម្មភាពនេះពី អ.ប.ព. ប្រសិនបើមាន។

៥. (១) ដឹកនាំ កសាងអង្គភាពសស្អាត និងមនុស្សល្អ ការងារល្អ សុចរិត (គ្មានអំពើពុករលួយ) នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ (២) ផ្សព្វផ្សាយ និងណែនាំអំពីគោលការណ៍អភិបាលកិច្ចល្អ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និង (៣) ជំរុញឱ្យមានការបង្កើត និងអនុវត្តនូវគោលនយោបាយចាំបាច់នានា ទាក់ទងនឹងអភិបាលកិច្ចល្អ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

៦. (១) រៀបចំបទប្បញ្ញត្តិអំពីការទទួលអំណោយសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ និង (២) ធ្វើរបាយការណ៍ប្រចាំខែអំពីអំណោយ និងមន្ត្រីដែលទទួលអំណោយ ការសម្រេចរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយទៅលើអំណោយនោះ មក អ.ប.ព.។

៧. (១) រៀបចំទម្រង់ប្រកាសទំនាស់ផលប្រយោជន៍ដែលមាន និងអាចមាន សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ និង (២) ធ្វើរបាយការណ៍ប្រចាំខែអំពីការប្រកាសទំនាស់ផលប្រយោជន៍ដែលមាន និងអាចមាននៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ មក អ.ប.ព.។

៨. ផ្តល់កិច្ចសហការក្នុងដំណើរការផ្តល់ចំណាត់ថ្នាក់ និងរង្វាន់សុចរិតភាពប្រចាំឆ្នាំ ដល់ក្រសួងអភិវឌ្ឍន៍ជនបទ។

PA

៩. (១) ផ្តល់ព័ត៌មាន និងកិច្ចសហការជាមួយក្រុមសិក្សាស្រាវជ្រាវរបស់ អ.ប.ព. ដើម្បីលុបបំបាត់លទ្ធភាព និងឱកាសប្រព្រឹត្តអំពើពុករលួយនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ និង (២) ជំរុញឱ្យមានការផ្លាស់ប្តូរដែលចាំបាច់ក្នុងផ្នែកដែលមានហានិភ័យខ្ពស់ នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។

១០. ចូលរួមការបណ្តុះបណ្តាលតាមការអញ្ជើញរបស់ អ.ប.ព. និងផ្តល់ការគាំទ្រចាំបាច់នានាដែលមានដល់ អ.ប.ព.។

**ប្រការ ៣** .- នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន គ្រប់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជា សុផារ៉ា**

**<u>ចម្លងជូន</u> :**

- ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
- ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ

  "<u>ដើម្បីជូនជ្រាប</u>"
- ដូចប្រការ ៣

  "<u>ដើម្បីអនុវត្ត</u>"
- ឯកសារ-កាលប្បវត្តិ